ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ...០៩០...ប្រ.ក...កសក

ប្រកាស
ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យនិងអង្គភាពចំណុះនាយកដ្ឋាន អភិវឌ្ឍន៍សហគមន៍កសិកម្មក្រោមឱវាទអគ្គនាយកដ្ឋានកសិកម្ម

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៨ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគមន៍កសិកម្ម
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានឋានៈស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧៩ អនក្រ.បក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មចំណុះអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ១០៩ ប្រក.កសក.ប ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋាន និងមន្ទីរពិសោធន៍ជាតិកសិកម្មក្រោមឱវាទអគ្គនាយកដ្ឋានកសិកម្ម

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

សម្រេច

ប្រការ ១.-

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ជានាយកដ្ឋានចំណុះឱ្យអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានការិយាល័យចំនួន៧ និងអង្គភាពចំណុះចំនួន១ ដូចខាងក្រោម៖

១-ការិយាល័យរដ្ឋបាល ផែនការ និងគណនេយ្យ

២-ការិយាល័យចុះបញ្ជីនិងជំរុញសហគមន៍កសិកម្ម

៣-ការិយាល័យអប់រំ បណ្តុះបណ្តាល និងសហប្រតិបត្តិការអន្តរជាតិ

៤-ការិយាល័យអភិវឌ្ឍមុខជំនួញនិងទីផ្សារ

៥-ការិយាល័យសវនកម្មសហគមន៍កសិកម្ម

៦-ការិយាល័យនីតិកម្មនិងដោះស្រាយវិវាទសហគមន៍កសិកម្ម

៧-ការិយាល័យតាមដាននិងវាយតម្លៃសហគមន៍កសិកម្ម

៨-មជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍសហគមន៍កសិកម្ម មានថ្នាក់ស្មើមន្ទីរកសិកម្មរាជធានី ខេត្ត ។

ប្រការ ២.-

ការិយាល័យនីមួយៗ និងអង្គភាពចំណុះមានភារកិច្ចដូចខាងក្រោម៖

២.១. ការិយាល័យរដ្ឋបាល ផែនការ និងគណនេយ្យ

- សម្របសម្រួលក្នុងការសិក្សានិងរៀបចំផែនការយុទ្ធសាស្ត្រថវិកាកម្មវិធីសកម្មភាពអភិវឌ្ឍសហគមន៍កសិកម្ម
- សម្របសម្រួលរាល់សកម្មភាពការងាររដ្ឋបាល
- គ្រប់គ្រងនិងចាត់ចងឯកសាររដ្ឋបាលរាល់សកម្មភាពការងាររដ្ឋបាលនិងការងារសង្គម
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាលនិងការងារពិធីការ
- ផ្តល់ការផ្តត់ផ្តង់សម្ភារ និងការជឹកជញ្ជូនដែលគាំទ្រដល់ប្រសិទ្ធភាពការងាររបស់នាយកដ្ឋាន
- ការពារសន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យក្នុងនាយកដ្ឋាន
- គ្រប់គ្រងសំណុំឯកសារដីវប្រវត្តិ ស្ថិតិ ក្របខ័ណ្ឌមន្ត្រីរាជការ
- សម្របសម្រួលរៀបចំបែបបទរដ្ឋបាលនិងឯកសារផ្សេងៗសម្រាប់ការបណ្តុះបណ្តាលមន្ត្រីឬទស្សនកិច្ចសិក្សាក្នុងនិងក្រៅប្រទេស
- រៀបចំឯកសារបៀវត្សពលកម្ម ប្រាក់កម្រៃ និងរបបឧបត្ថម្ភដោយសហការជាមួយនាយកដ្ឋានរដ្ឋបាលផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិនៃអគ្គនាយកដ្ឋានកសិកម្ម
- លើកសំណើសុំផ្ទេរ ដំឡើងឋានៈ លើកសរសើរ ដាក់វិន័យ ឬកែសម្រួលចនាសម្ព័ន្ធតាមស្ថានភាពជាក់ស្តែង
- ធ្វើរបាយការណ៍ទូទាត់ថវិកាចំណូលចំណាយក្នុងការអនុវត្តថវិការដ្ឋនិងគម្រោងផ្សេងៗរបស់នាយកដ្ឋាន
- រៀបចំនិងគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ បញ្ជីសារពើភ័ណ្ឌ ទ្រព្យសម្បត្តិ និងសម្ភារបរិក្ខាររបស់នាយកដ្ឋាន
- គ្រប់គ្រងសន្និធិនិងបែងចែកមធ្យោបាយ សម្ភារ បរិក្ខារ និងប្រេងឥន្ធនៈរបស់នាយកដ្ឋាន

- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាពនិងលទ្ធផលការងារ របស់នាយកដ្ឋាន ដោយធ្វើការបូកសរុបរបាយការណ៍និងការងារផ្សេងៗ ពីបណ្តាការិយាល័យចំណុះនាយកដ្ឋាន
- សរុបរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំស្តីពីសកម្មភាពនិងលទ្ធផលការងារ របស់នាយកដ្ឋានដោយធ្វើការបូកសរុបរបាយការណ៍និងការងារផ្សេងៗពីបណ្តាការិយាល័យចំណុះនាយកដ្ឋាន
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ ។

២.២.ការិយាល័យចុះបញ្ជីនិងជំរុញសហគមន៍កសិកម្ម

- កសាងផែនការសកម្មភាពការងាររបស់ការិយាល័យ
- សិក្សារៀបចំនិងផ្សព្វផ្សាយឯកសារបច្ចេកទេសស្តីពីនីតិវិធីបង្កើតនិងចុះបញ្ជីសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- សម្របសម្រួលការបង្កើតនិងការចុះបញ្ជីទទួលស្គាល់សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- ប្រមូល វិភាគ ធ្វើបច្ចុប្បន្នភាពនិងគ្រប់គ្រងទិន្នន័យ និងព័ត៌មានសហគមន៍កសិកម្ម
- សម្របសម្រួលរៀបចំសន្និបាតសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាថ្នាក់ជាតិ
- សម្របសម្រួល និងគាំទ្របច្ចេកទេសដល់ការរៀបចំនិងអភិវឌ្ឍន៍អង្គការកសិករ
- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាពនិងលទ្ធផលការងារ របស់ការិយាល័យ
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ ។

២.៣.ការិយាល័យអប់រំ បណ្តុះបណ្តាល និងសហប្រតិបត្តិការអន្តរជាតិ

- កសាងផែនការសកម្មភាពនិងកម្មវិធីបណ្តុះបណ្តាលសម្រាប់ជំរុញការពង្រឹងសមត្ថភាពនិងការអភិវឌ្ឍសហគមន៍កសិកម្ម
- ធ្វើទំនាក់ទំនងសម្របសម្រួលផ្លាស់ប្តូរព័ត៌មានការងារសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ និងផ្នែកឯកជនលើការងារអភិវឌ្ឍសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- សិក្សាវាយតម្លៃពីតម្រូវការបណ្តុះបណ្តាលបច្ចេកទេសដឹកនាំ គ្រប់គ្រង និងមុខជំនួញសហគមន៍កសិកម្ម
- សិក្សានិងរៀបចំឯកសារបច្ចេកទេសសម្រាប់បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពសហគមន៍កសិកម្ម
- បណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពដល់ភ្នាក់ងារអភិវឌ្ឍសហគមន៍កសិកម្ម
- អប់រំ កសាង និងពង្រឹងសមត្ថភាពថ្នាក់ដឹកនាំនិងសមាជិកសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- អនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងនិងការបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពរបស់សហគមន៍កសិកម្ម

- សម្របសម្រួលនិងគាំទ្របច្ចេកទេសកសិកម្ម រ៉ារីវិប្បកម្មកៅស៊ូ និងក្សេត្រ-រុក្ខកម្មដល់សហគមន៍កសិកម្ម និងសហភាពសហគមន៍កសិកម្ម
- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាពនិងលទ្ធផលការងាររបស់ការិយាល័យ
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ ។

២.៤. ការិយាល័យអភិវឌ្ឍមុខជំនួញនិងទីផ្សារ

- កសាងផែនការសកម្មភាពការងាររបស់ការិយាល័យ
- សម្របសម្រួលការធ្វើមុខជំនួញនិងទីផ្សាររវាងសហគមន៍កសិកម្ម និងសហភាពសហគមន៍កសិកម្មជាមួយផ្នែកឯកជន ដៃគូអភិវឌ្ឍ ឬផ្នែកពាក់ព័ន្ធផ្សេងទៀត
- សម្របសម្រួលសហគមន៍កសិកម្ម និងសហភាពសហគមន៍កសិកម្មក្នុងការបង្កើតទីផ្សារ
- ប្រមូល ចងក្រង និងផ្សព្វផ្សាយព័ត៌មានមុខជំនួញ និងព័ត៌មានទីផ្សារដល់សហគមន៍កសិកម្មនិងអ្នកពាក់ព័ន្ធ
- សម្របសម្រួល រៀបចំវេទិកាមុខជំនួញ និងការតាំងពិព័រណ៍ផលិតផលរបស់សហគមន៍កសិកម្ម
- ជំរុញការអភិវឌ្ឍមុខជំនួញរបស់សហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្ម
- សិក្សារៀបចំចងក្រងនិងផ្សព្វផ្សាយករណីសិក្សាស្តីពីមុខជំនួញរបស់សហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្ម
- សិក្សានិងវាយតម្លៃពីស្ថានភាពសេដ្ឋកិច្ចរបស់សហគមន៍កសិកម្ម និងសហភាពសហគមន៍កសិកម្មដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារ ព្រមទាំងផ្តល់ព័ត៌មានទីផ្សារកសិផលដល់សហគមន៍កសិកម្ម និងសហភាពសហគមន៍កសិកម្ម
- បង្កើតកម្មវិធីផ្សព្វផ្សាយនិងលើកកម្ពស់ការយល់ដឹងអំពីការអភិវឌ្ឍមុខជំនួញនិងទីផ្សារដល់សហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្ម
- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាពនិងលទ្ធផលការងាររបស់ការិយាល័យ
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ ។

២.៥.ការិយាល័យនីតិកម្មនិងដោះស្រាយវិវាទសហគមន៍កសិកម្ម

- កសាងផែនការសកម្មភាពការងារការិយាល័យ
- សិក្សានិងរៀបចំគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីសហគមន៍កសិកម្ម
- ផ្សព្វផ្សាយគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីសហគមន៍កសិកម្មព្រមទាំងច្បាប់ពាក់ព័ន្ធដល់សហគមន៍កសិកម្មនិងអ្នកពាក់ព័ន្ធ
- សិក្សានិងដោះស្រាយបណ្តឹងតវ៉ារបស់គណៈកម្មការរៀបចំបង្កើតសហគមន៍កសិកម្មស្តីពីការបដិសេធចុះបញ្ជីទទួលស្គាល់សហគមន៍កសិកម្មរបស់មន្ទីរកសិកម្មរាជធានី ខេត្ត
- ចូលរួមសិក្សាវាយតម្លៃនិងសម្របសម្រួលដោះស្រាយបណ្តឹងតវ៉ា និងវិវាទរបស់សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា

- ចូលរួមតាមដាននិងវាយតម្លៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីសហគមន៍កសិកម្ម របស់សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- លើកសំណើនិងវិធានការពាក់ព័ន្ធចំពោះការអនុវត្តខុសឆ្គងលើនីតិវិធីនិងច្បាប់ពាក់ព័ន្ធជាធរមាន របស់សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្ម ជូននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម
- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាពនិងលទ្ធផលការងារ របស់ការិយាល័យ
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ ។

២.៦. ការិយាល័យសវនកម្មសហគមន៍កសិកម្ម

- កសាងផែនការសកម្មភាពការងារការិយាល័យ
- សិក្សានិងរៀបចំឯកសារចុះបញ្ជីគណនេយ្យគំរូសម្រាប់ឱ្យសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាយកទៅប្រើប្រាស់
- ណែនាំពីនីតិវិធីចុះបញ្ជីគណនេយ្យដល់សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- បណ្តុះបណ្តាលពង្រឹងសមត្ថភាពរបស់សវនករផ្ទៃក្នុងរបស់សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- ត្រួតពិនិត្យបច្ចេកទេសលើការចុះបញ្ជីគណនេយ្យរបស់សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- ត្រួតពិនិត្យបច្ចេកទេសលើការគ្រប់គ្រងដំនួញរបស់សហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្ម
- ផ្តល់ដំនួយបច្ចេកទេសលើការរៀបចំតារាងតុល្យការនិងរបាយការណ៍ហិរញ្ញវត្ថុរបស់សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- តាមដានការអនុវត្តកាតព្វកិច្ចសវនកម្មរបស់សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- ចូលរួមតាមដានការធ្វើសវនកម្មផ្ទៃក្រៅរបស់សវនករចំពោះសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- សិក្សារៀបចំកម្មវត្ថុសវនកម្មសម្រាប់សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- សម្របសម្រួលការងារដម្រះបញ្ជីសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាក្នុងករណីដែលត្រូវបានរំលាយ
- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាពនិងលទ្ធផលការងារ របស់ការិយាល័យ
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ ។

២.៧. ការិយាល័យតាមដាននិងវាយតម្លៃសហគមន៍កសិកម្ម

- កសាងផែនការសកម្មភាពការងាររបស់ការិយាល័យ
- តាមដាន និងវាយតម្លៃរាល់ដំណើរការប្រតិបត្តិការមុខរបរ និងការប្រព្រឹត្តទៅរបស់សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- ត្រួតពិនិត្យ និងវាយតម្លៃការប្រើប្រាស់ថវិការបស់មូលនិធិអភិវឌ្ឍន៍សហគមន៍កសិកម្ម
- តាមដាន និងវាយតម្លៃពីប្រសិទ្ធភាពនៃការអនុវត្តថវិកាជាតិនិងថវិកាដៃគូអភិវឌ្ឍ និងថវិកាពីប្រភពផ្សេងទៀតលើការងារអភិវឌ្ឍសហគមន៍កសិកម្ម
- បង្កើត និងគ្រប់គ្រងប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃលើវឌ្ឍនភាពរបស់សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាពនិងលទ្ធផលការងាររបស់ការិយាល័យ
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ ។

២.៨.មជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍសហគមន៍កសិកម្ម

- កសាងផែនការសកម្មភាពរបស់មជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍសហគមន៍កសិកម្ម
- សិក្សាស្រាវជ្រាវនិងចងក្រងឯកសារបច្ចេកទេសសម្រាប់ការបណ្តុះបណ្តាល និងផ្សព្វផ្សាយដល់សហគមន៍កសិកម្ម និងអ្នកពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវប្រមូលផ្តុំនិងគ្រប់គ្រងឯកសារពាក់ព័ន្ធ និងបទពិសោធន៍ទាក់ទងនឹងសហគមន៍កសិកម្ម
- សិក្សាវាយតម្លៃពីស្ថានភាពនិងតម្រូវការបណ្តុះបណ្តាល និងអភិវឌ្ឍសហគមន៍កសិកម្ម
- កសាងផែនការបណ្តុះបណ្តាលនិងអភិវឌ្ឍសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- ផ្តល់សេវាកម្មបណ្តុះបណ្តាលដល់សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា និងភ្នាក់ងារអភិវឌ្ឍសហគមន៍កសិកម្ម
- រៀបចំកម្មវិធីសិក្សារយៈពេលខ្លី មធ្យម និងវែងសម្រាប់បណ្តុះបណ្តាលដល់ភ្នាក់ងារអភិវឌ្ឍសហគមន៍កសិកម្ម ការងារអភិវឌ្ឍសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- ធ្វើកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌជាតិនិងអន្តរជាតិស្តីពីសហគមន៍កសិកម្ម
- សម្របសម្រួលរៀបចំកម្មវិធីទស្សនកិច្ចសិក្សាសម្រាប់សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជានៅក្នុងស្រុកនិងក្រៅប្រទេស
- សម្របសម្រួលជាមួយគ្រឹះស្ថានសិក្សាដែលពាក់ព័ន្ធដើម្បីដាក់បញ្ចូលកម្មវិធីសិក្សាស្តីពីសហគមន៍កសិកម្មទៅក្នុងកម្មវិធីសិក្សារបស់គ្រឹះស្ថានសិក្សាទាំងនោះ
- បង្កើតនិងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យានៃសហគមន៍កសិកម្ម(ITC)
- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាពនិងលទ្ធផលការងាររបស់មជ្ឈមណ្ឌល

– ទទួលការកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ ។

ប្រការ៣.–

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍសហគមន៍កសិកម្ម ត្រូវកំណត់ដោយប្រកាសដោយឡែក។

ប្រការ៤.–

- ការិយាល័យ និងអង្គភាពចំណុះនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់
- ប្រធានការិយាល័យ និងប្រធានអង្គភាពចំណុះត្រូវទទួលខុសត្រូវចំពោះមុខប្រធាននាយកដ្ឋាន និងអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្មនូវគ្រប់សកម្មភាពការងារដែលបានអនុវត្ត
- អនុប្រធានការិយាល័យ និងអនុប្រធានអង្គភាពចំណុះ ជាជំនួយការឱ្យប្រធាន និងត្រូវបានប្រធានប្រគល់ការងារមួយចំនួនឱ្យទទួលបន្ទុក និងទទួលខុសត្រូវចំពោះមុខប្រធាន នូវគ្រប់សកម្មភាពការងារនោះ ព្រមទាំងត្រូវរួមគ្នាជាមួយប្រធាន ក្នុងការទទួលខុសត្រូវគ្រប់សកម្មភាពការងារដែលបានអនុវត្ត។

ប្រការ ៥.–

ប្រកាសលេខ ១០៩ ប្រក.កសក ប ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋាន និងមន្ទីរពិសោធន៍ជាតិកសិកម្មក្រោមឱវាទអគ្គនាយកដ្ឋានកសិកម្ម នៅជាធរមានដដែលលើកលែងតែចំណុចទី៥ និងចំណុចទី៩.៥ ក្នុងប្រការទី៩ នៃប្រកាសនេះ។

ប្រការ ៦.–

អគ្គលេខាធិការ អគ្គាធិការ នាយកឧទ្ធកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ និងប្រធានអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមការកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥

រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

បណ្ឌិត អ៊ឹក រ៉ាប៊ុន

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ឧទ្ធកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ឧទ្ធកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គ្រប់មន្ទីរកសិកម្ម រាជធានី ខេត្ត
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឧបសម្ព័ន្ធនៃប្រកាសលេខ.០.៤.០.....ប្រក.កសក.ប ចុះថ្ងៃទី.២.៤...ខែ.ម.ក.....ឆ្នាំ២០១៥

អង្គការលេខរបស់នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម